សាជីវកម្មធានាឥណទានកម្ពុជា
CREDIT GUARANTEE CORPORATION OF CAMBODIA

ບໍລິສັດ ຄ້ຳປະກັນສິນເຊື່ອລາວ ຈຳກັດຜູ້ດຽວ
LAO CREDIT GUARANTEE SOLE COMPANY LIMITED

# សេចក្ដីប្រកាសព័ត៌មាន
# ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង
# សាជីវកម្មធានាឥណទានកម្ពុជា និងក្រុមហ៊ុនធានាឥណទានឡាវ

នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៦ នៅការិយាល័យសាជីវកម្មធានាឥណទានកម្ពុជា (CGCC), មានការចុះហត្ថលេខាជាផ្លូវការលើអនុស្សរណៈនៃការយោគយល់គ្នា រវាង CGCC និង Lao Credit Guarantee Sole Company Limited (LCGC) ដើម្បីបង្កើតក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងស្ថាប័នធានាឥណទានទាំងពីរ ក្នុងគោលបំណងគាំទ្រដល់ការអភិវឌ្ឍសេវាធានាឥណទាន និងភាពរីកចម្រើនប្រកបដោយស្ថេរភាពរបស់សហគ្រាសធុន មីក្រូ តូច និងមធ្យម (MSMEs) ក្នុងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

អនុស្សរណៈនៃការយោគយល់គ្នានេះ ត្រូវបានចុះហត្ថលេខាដោយលោក ណូ លីដា អគ្គនាយក CGCC និងលោក Wong Keet Loong អគ្គនាយក LCGC ក្រោមវត្តមានជាសាក្សីពីថ្នាក់ដឹកនាំជាន់ខ្ពស់មកពីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម, ក្រសួងហិរញ្ញវត្ថុ, និងធនាគារជាតិនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ព្រមទាំងថ្នាក់គ្រប់គ្រង និងក្រុមការងាររបស់ CGCC សរុបប្រមាណ ៣០រូប។

**លោក ណូ លីដា អគ្គនាយក CGCC** បានថ្លែងថា *"អនុស្សរណៈនៃការយោគយល់គ្នារវាង CGCC និង LCGC នឹងនាំមកនូវអត្ថប្រយោជន៍រួម តាមរយៈកិច្ចសហប្រតិបត្តិការនៅក្នុងការអភិវឌ្ឍសមត្ថភាព, ការផ្លាស់ប្ដូរព័ត៌មាន, និងការកែលម្អប្រតិបត្តិការអាជីវកម្ម។ អនុស្សរណៈយោគយល់នេះ គឺជាចំណុចចាប់ផ្ដើមនៃភាពជាដៃគូយូរអង្វែង និងមានឥទ្ធិពលរវាងស្ថាប័នទាំងពីរ។ ការច្នៃប្រឌិត មិនត្រូវបានកំណត់ដោយអាយុកាលនៃស្ថាប័ននោះទេ។ ទោះបីជា CGCC បានចាប់ផ្ដើមដំណើរការមុន LCGC ក៏ដោយ ក៏មានចំណុចដែល LCGC អាចអនុវត្តបានល្អជាង CGCC ហើយ CGCC ស្វាគមន៍ឱកាសទាំងនោះ ដើម្បីរៀនសូត្រ ដកបទពិសោធន៍ និងអភិវឌ្ឍរួមគ្នា។"*

**លោក** Wong Keet Loong **អគ្គនាយក LCGC** បានថ្លែងថា *"អនុស្សរណៈនៃការយោគយល់គ្នានេះ ត្រូវបានរៀបចំឡើងដើម្បីបង្កើតក្របខណ្ឌរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់កិច្ចសហប្រតិបត្តិការរវាង CGCC និង LCGC ក្នុងការអភិវឌ្ឍ និងអនុវត្តគម្រោងធានាឥណទាន ដើម្បីគាំទ្រ ដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ព្រមទាំងការផ្លាស់ប្ដូរចំណេះដឹងស្ដីពី ហិរញ្ញប្បទានបៃតង និងគម្រោងធានាឥណទានសម្រាប់ហិរញ្ញប្បទានបៃតង។ ក្នុងនាមជាស្ថាប័នធានាឥណទានដែលបង្កើតឡើងដោយរដ្ឋាភិបាល ស្ថាប័នទាំងពីរមានទិសដៅរួមក្នុងការកាត់បន្ថយឧបសគ្គ និងគម្លាតក្នុងការទទួលបានហិរញ្ញប្បទានសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ដែលជាវិស័យសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនៅទូទាំងតំបន់។"*

## **អំពី** CGCC

CGCC គឺជាសហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។ CGCC មានបេសកកម្មចម្បងក្នុងការផ្ដល់ការធានាឥណទាន ដើម្បីបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ច។ ផលិតផល និងសេវាកម្មសំខាន់ៗរបស់ CGCC រួមមាន ការធានាលើកម្ចី

អាជីវកម្ម ការធានាលើការបោះផ្សាយសញ្ញាបណ្ណ និងការកសាងសមត្ថភាពសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs)។ គិតត្រឹមបំណាច់ខែមេសា ឆ្នាំ២០២៦ CGCC បានផ្តល់ការធានាលើកម្ចីអាជីវកម្មចំនួន ៩.៨០៨ គណនី ក្នុងទំហំសរុប ៥៦៧,៦៣ លានដុល្លារអាមេរិក។

**អំពី** LCGC

LCGC គឺជាសហគ្រាសសាធារណៈ ស្ថិតក្រោមការត្រួតពិនិត្យពីធនាគារជាតិនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងក្រោមអាណាព្យាបាលបច្ចេកទេសពីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម និងជាស្ថាប័នកម្មសិទ្ធិរបស់ក្រសួងហិរញ្ញវត្ថុ។ LCGC ត្រូវបានចុះបញ្ជីបង្កើតជាផ្លូវការនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤។ LCGC មានទិសដៅក្នុងការលើកកម្ពស់ការទទួលបានហិរញ្ញប្បទានសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) តាមរយៈការផ្តល់ការធានាឥណទានដល់គ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យក្នុងការផ្តល់កម្ចី និងជំរុញកំណើនឥណទានរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ៕

ថ្ងៃចន្ទ ១០រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៦

**សាជីវកម្មធានាឥណទានកម្ពុជា**